Transportation Security Administration

ការគ្រប់គ្រងសន្តិសុខ
នៃការដឹកជញ្ជូន

# ការបង្ហាញ និង ការបញ្ជាក់ បណ្ណ័សំគាល់អត្តសញ្ញាណ ជាអ្នកធ្វើការដឹកជញ្ជូន

**ការណែនាំ:** ប្រសិនបើអ្នកចាំបាច់ត្រូវមានបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន អ្នកត្រូវតែឆ្លងកាត់ការវាយតំលៃលើផ្នែកគំរាមសន្តិសុខ ។ ដើម្បីឆ្លងកាត់ការវាយតំលៃនេះ អ្នកសុំចូលបំរើការទាំងអស់ត្រូវចាំបាច់ផ្តល់ពត៌មានតាមការទាមទារខាងក្រោម ហើយនិងឯកសារត្រឹមត្រូវសំរាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណ របស់ពួកគេ ព្រមទាំងស្ថានភាពអន្តោប្រវេសន៍ប្រសិនបើត្រូវមាន) ដែលជាផ្នែកមួយនៃដំណើរការចុះឈ្មោះ ។ សំណុំបែបបទដែលបំពេញរួចហើយត្រូវយកទៅដាក់ដោយខ្លួនឯង នៅពេលចាប់ផ្តើមដំណើរការចុះឈ្មោះ ។ ប្រសិនបើអ្នកពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាំងពីដំបូង អ្នកអាចមានសិទ្ធិបានបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូនដោយត្រូវដាក់ពាក្យសុំការលើកលែងអ្វីមួយ ដែលផ្តល់អោយអ្នកនូវឱកាសសំរាប់ផ្តល់ពត៌មានបន្ថែមនិងឯកសារផ្សេងៗ ដែលជួយគាំទ្រដល់ភាពស្របច្បាប់របស់អ្នក ។ អ្នកត្រូវរង់ចាំលិខិតសម្រេច ដំបូងពីការវាយតំលៃលើភាពគំរាមសន្តិសុខ មុននឹងដាក់ពាក្យសុំការលើកលែងអ្វីមួយ ។

| ភាគ ១ - ការបង្ហាញ | |
|---|---|
| **ផ្នែក ក: ការទទួលស្គាល់** - ពិនិត្យមើលឡើងវិញនូវឃ្លាប្រយោគនិមួយៗ និងផ្តល់ចំឡើយដោយគូសក្នុងប្រអប់ **បាទ** ឬ **ទេ** អោយបានត្រឹមត្រូវ ។ | |
| ១- ជាផ្នែកមួយនៃភារកិច្ចការងាររបស់ខ្ញុំ:<br>• ខ្ញុំត្រូវ ឬ ភាគច្រើន នឹងត្រូវតំរូវអោយចូលដោយពុំមានអ្នកអមដំណើរ ទៅកាន់តំបន់ការពារនៃសេវាកម្មផ្លូវទឹក ឬនាវា ដែលនៅកន្លែងនោះគេតំរូវអោយមានបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន ។<br>• បច្ចុប្បន្នខ្ញុំជា ឬ ខ្ញុំកំពុងដាក់ពាក្យសុំធ្វើជា អ្នកដើរកប៉ាល់ជំនួញ ឬ<br>• ខ្ញុំជាអ្នកមានបណ្ណ័បើកបរប្រភេទពាណិជ្ជកម្ម នៅក្នុងប្រទេសកាណាដា និងមិចស៊ីកូ សំរាប់ដឹកជញ្ជូនសំភារៈដែលមានគ្រោះថ្នាក់ និង/ឬ ធ្វើជំនួញនៅក្នុងសហរដ្ឋអាមេរិក ។ | ☐ បាទ ☐ ទេ |
| ២- ខ្ញុំយល់ហើយថា បើសិនជាខ្ញុំគ្រោងដាក់ពាក្យសុំ ឬសុំបន្តបណ្ណ័សំគាល់ជាអ្នកដើរកប៉ាល់ ដែលចេញអោយដោយឆ្មាំសមុទ្រ ប៉ុន្តែមិនផ្តល់លេខសន្តិសុខសង្គមរបស់ខ្ញុំ និងភស្តុតាងស្តីពីសញ្ជាតិនៅពេលចុះឈ្មោះទេនោះ ខ្ញុំនឹងត្រូវតំរូវអោយទៅកាន់មណ្ឌលត្រួតពិនិត្យឆ្មាំសមុទ្រប្រចាំតំបន់ ដើម្បីផ្តល់ពត៌មានទាំងនេះ មុនពេលពាក្យស្នើសុំបណ្ណ័សំគាល់របស់ខ្ញុំ ដែលចេញដោយឆ្មាំសមុទ្រ ត្រូវត្រួតពិនិត្យពេញលេញ ។ | ☐ បាទ ☐ ទេ |
| ៣- ខ្ញុំទទួលស្គាល់ថា ប្រសិនបើការគ្រប់គ្រងសន្តិសុខនៃការដឹកជញ្ជូន ឬទីភ្នាក់ងារអនុវត្តច្បាប់ផ្សេងៗ កំណត់ថាខ្ញុំអាចបង្កការគំរាមកំហែងណាមួយនៅថ្ងៃខាងមុខ ចំពោះសន្តិសុខជាតិ ឬសន្តិសុខនៃការ | |

| | |
|---|---|
| ដឹកជញ្ជូន គេអាចរាយការណ៍អោយនិយោជកខ្ញុំ ។ ការគ្រប់គ្រងសន្តិសុខនៃការដឹកជញ្ជូនអាចផ្តល់ព័ត៌មានតែមួយចំនួនប៉ុណ្ណោះ ចំពោះជំនាញសេវាកម្ម និងនាវា ។ **កំណត់ចំណាំ:** ក្រដាសលទ្ធផលរបស់ការិយាល័យស៊ើបអង្កេតសហព័ន្ធនឹងមិនត្រូវអោយនិយោជកដឹងទេ ។ | ☐ បាទ ☐ ទេ |
| ៤- ខ្ញុំយល់ហើយថា ដោយបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូននឹងត្រូវប្រើដូចជាផ្លាកសំគាល់អត្តសញ្ញាណរូបភាព វត្ថុនានាឬសំលៀកបំពាក់មិនត្រូវបិទបាំងផ្នែកណាមួយនៃមុខរបស់ខ្ញុំ នៅពេលគេថតរូបខ្ញុំទេ។ ជាលទ្ធផល ខ្ញុំទទួលស្គាល់ថា:<br>• ខ្ញុំនឹងដោះមួក ឬអ្វីដែលពាក់លើក្បាល លើកលែងតែរបស់ទាំងនេះត្រូវពាក់ប្រចាំថ្ងៃ ដោយសារបុព្វហេតុសាសនា ។<br>• ខ្ញុំនឹងដោះវ៉ែនតាដែលមានកញ្ចក់ពណ៌ខ្មៅ ឬកញ្ចក់ពណ៌ស្រអាប់ដែលមិនតំរូវអោយពាក់ដោយវេជ្ជបញ្ជា លើកលែងតែវ៉ែនតាទាំងនោះត្រូវបានតំរូវអោយពាក់ជារៀងរាល់ពេល ដោយសារបុព្វហេតុ សុខភាព។ បើសិនជាដូច្នេះមែន ត្រូវទាមទារអោយមានលិខិតបញ្ជាក់ ពីសុខភាព ។ | ☐ បាទ ☐ ទេ |
| ៥- ខ្ញុំជា:<br>• ពលរដ្ឋអាមេរិក ឬ ជនជាតិអាមេរិក ☐ បាទ ☐ ទេ<br>• មិនមែនជាពលរដ្ឋអាមេរិក ឬ ជនជាតិអាមេរិក ប៉ុន្តែស្ថិតនៅក្នុងប្រភេទដែលមានចែងនៅក្នុងទំព័រទី៧,៨,៩ ដែលអនុញ្ញាតអោយខ្ញុំកាន់បណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន ។ ☐ បាទ ☐ ទេ | |
| ៦- បច្ចុប្បន្ននេះ ខ្ញុំមិនមែនជាអ្នកកាន់បណ្ណ័សំគាល់អត្តសញ្ញាណធ្វើការដឹកជញ្ជូនទេ ។ | ☐ បាទ ☐ ទេ |
| **ផ្នែក ខ: ប្រវត្តិឧក្រិដ្ឋកម្ម** - ពិនិត្យមើលឃ្លាប្រយោគនិមួយៗឡើងវិញ ហើយនិងផ្តល់ចំឡើយដោយគូសក្នុងប្រអប់ **បាទ** ឬ **ទេ** អោយបានត្រឹមត្រូវ (សូមអានយោងនៅទំព័រ ១០,១១,១២ សំរាប់ពត៌មានបន្ថែមទៀត) | |
| ១- នៅក្នុងពេលណាមួយនៃជីវិតរបស់ខ្ញុំ (ដោយមិនគិតពីរឿងក្តីកាលនៅវ័យជំទង់ លើកលែងតែត្រូវកាត់ទោសដូចមនុស្សពេញវ័យ) ខ្ញុំត្រូវបានកាត់ក្តីអោយមានទោស ឬ ឆ្លើយទទួលកំហុស (រួមទាំង "ការមិនប្រឆាំងតវ៉ា") ឬ ត្រូវបានរកឃើញថាមិនមានកំហុស ដោយមូលហេតុនៃជំងឺសរសៃប្រសាទ នៅក្នុងតុលាការស៊ីវិល ឬ តុលាការយោធា លើក្តីមួយ ឬ ច្រើននៃបទឧក្រិដ្ឋខាងក្រោម:<br>• ចារកម្ម ឬ ការរួមគំនិតធ្វើចារកម្ម<br>• ការនាំបះបោរ ឬ ការរួមគំនិតបំបះបំបោរ<br>• ការក្បត់ជាតិ ឬ ការរួមគំនិតក្បត់ជាតិ ឬ<br>• បទឧក្រិដ្ឋភេរវកម្មសហព័ន្ធដូចមានចែងនៅក្នុងលេខ ១៨ U.S.C.២៣៣២(g) ឬច្បាប់រដ្ឋផ្សេងៗដែលដូចគ្នា ។<br>**កំណត់ចំណាំ:** បើសិនជាអ្នកឆ្លើយ "បាទ" អ្នកមិនមានសិទ្ធិបានទទួលបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកដឹកជញ្ជូន និង/ឬលិខិតលើកលែងអ្វីមួយឡើយ ។ | ☐ បាទ ☐ ទេ |
| ២- នៅក្នុងពេលណាមួយនៃជីវិតរបស់ខ្ញុំ (ដោយមិនគិតពីរឿងក្តីកាលនៅវ័យជំទង់ លើកលែងតែត្រូវកាត់ទោសដូចមនុស្សពេញវ័យ) ខ្ញុំត្រូវបានកាត់ក្តីអោយមានទោស ឬឆ្លើយទទួលកំហុស (រួមទាំង "ការមិនប្រឆាំងតវ៉ា") ឬត្រូវបានរកឃើញថាមិនមានកំហុស ដោយមូលហេតុនៃជំងឺសរសៃប្រសាទ នៅក្នុងតុលាការស៊ីវិល ឬតុលាការយោធា លើក្តីមួយ ឬច្រើននៃបទឧក្រិដ្ឋខាងក្រោម: | ☐ បាទ ☐ ទេ |

- ឧក្រិដ្ឋកម្មទាក់ទងនឹងឧប្បត្តិហេតុសន្តិសុខនៃការដឹកជញ្ជូន
- ការដឹកជញ្ជូនមិនត្រឹមត្រូវនៃសំភារៈប្រកបដោយគ្រោះថ្នាក់
- កម្មសិទ្ធិមិនស្របច្បាប ការប្រើប្រាស់ ការលក់ ការចែកចាយ ការផលិត ការទិញ ...ឬពាក់ពន្ធ័នឹងរំសេវផ្ទុះ ឬគ្រឿងផ្ទុះ
- ឃាតកម្ម
- ធ្វើការគំរាមកំហែង ឬក្នុងបំណងអាក្រក់នាំពតិមានក្លែងក្លាយដែលដឹងថាមិនពិត ដែលទាក់ទងនឹងប្រគល់របស់ ការដាក់ ឬការធ្វើអោយផ្ទុះ គ្រឿងរំសេវ ឬគ្រឿងផ្ទុះផ្សេងៗដែលបណ្តាលអោយស្លាប់បាន នៅក្នុងទីសាធារណៈ អាគាររដ្ឋាភិបាល ការដឹកជញ្ជូនសាធារណៈ ឬហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗ
- ការរំលោភច្បាប់ស្តីពីការបង្កអំពើពុករលួយ និងអ្នកបោកប្រាស់ ដែលក្នុងនេះមានបទល្មើស ដែលជាឧក្រិដ្ឋកម្ម ដូចមាននចែងនៅក្នុងផ្នែក ខ១ និង ខ២
- ប៉ុនប៉ងធ្វើឧក្រិដ្ឋកម្ម ដូចមានចែងនៅក្នុងផ្នែកខ១ និង ខ២ ឬ
- ការរួមគំនិត ឬការប៉ុនប៉ងធ្វើឧក្រិដ្ឋកម្ម ដូចមានចែងក្នុងផ្នែក ខ២ ។

៣- ក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយ ខ្ញុំត្រូវបានកាត់ក្តីអោយមានទោស ឆ្លើយទទួលកំហុស (រួមទាំង “ការមិនប្រឆាំងតវ៉ា”) ឬត្រូវបានរកឃើញថាមិនមានកំហុស ដោយមូលហេតុនៃជំងឺសរសៃប្រសាទ នៅក្នុងតុលាការស៊ីវិល ឬតុលាការយោធា លើក្តីណាមួយនៃបទឧក្រិដ្ឋខាងក្រោម: ☐ បាទ ☐ ទេ

- កម្មសិទ្ធិមិនស្របច្បាប់ ការប្រើប្រាស់ ការលក់ ការផលិត ការទិញ ការចែកចាយ...ឬពាក់ពន្ធ័នឹងកាំភ្លើងដៃ ឬអាវុធផ្សេងទៀត
- ការគំរាមកំហែងយកប្រាក់
- ភាពមិនស្មោះត្រង់ ការបន្លំ ឬការក្លែងធ្វើជាតំណាង រួមទាំងការបន្លំអត្តសញ្ញាណ ការលាងលុយក្រខ្វក់ (លើកលែងតែការបន្លំប្រាក់សង្គ្រោះ និងការប្រើសែកធនាគារដែលគ្មានលុយ)
- ការស៊ីសំណូក
- ការរត់ពន្ធ
- ការរំលោភច្បាប់អន្តោប្រវេសន៍
- ការចែកចាយ ការមានជាប់នឹងខ្លួនក្នុងបំណងចង់ចែកចាយ ឬការនាំចូលនូវសារធាតុគ្រឿងញៀន
- ការបង្កអគ្គីភ័យ
- ការចាប់ជំរិត ឬ ចាប់ជាចំណាប់ខ្មាំង
- ការចាប់រំលោភ ឬ ការរំលោភផ្លូវភេទដ៏ធ្ងន់ធ្ងរ
- ការវាយតប់ក្នុងគោលបំណងចង់សំលាប់
- ការប្លន់
- ការបន្លំចូលទៅក្នុងកំពង់ផែ
- ការរំលោភច្បាប់ស្តីពីការបង្កអំពើពុករលួយ និងអ្នកបោកប្រាស់ **ឬ**
- ការរួមគំនិត ឬប៉ុនប៉ងធ្វើឧក្រិដ្ឋកម្ម ដូចមានចែងក្នុង ផ្នែក ខ៣

៤- ក្នុងរយៈពេល **៥** ឆ្នាំចុងក្រោយ ខ្ញុំត្រូវបានដោះលែងចេញពីមន្ទីរឃុំឃាំងបន្ទាប់ពីជាប់ទោស ពីបទឧក្រិដ្ឋដូចមានចែងក្នុងផ្នែក ខ៣ ☐ បាទ ☐ ទេ

៥- ខ្ញុំជាមនុស្សដែលគេស្វែងរកចាប់ខ្លួន ឬក្រោមដីការចោទប្រកាន់នៅតុលាការស៊ីវិល ឬយោធា ពីបទឧក្រិដ្ឋដូចមានចែងក្នុងផ្នែក ខ១ រហូតដល់ ខ៣ ☐ បាទ ☐ ទេ

៦- តុលាការស៊ីវិល ឬ យោធាបានរកឃើញថាខ្ញុំមានសតិបញ្ញាមិនគ្រប់គ្រាន់ ឬ ខ្ញុំបានព្យាបាលជំងឺសសៃប្រសាទនេះដោយបង្ខំ នៅក្នុងមន្ទីរពេទ្យ ☐ បាទ ☐ ទេ

| | |
|---|---|
| **កំណត់ចំណាំ:** បើសិនជាអ្នកឆ្លើយថា "បាទ" ទៅនឹងបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងផ្នែក ខ២ ដល់ ខ៦ អ្នកមានសិទ្ធិសុំលិខិតលើកលែងណាមួយ និងនៅតែបានទទួលបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន ។ បើសិនជាអ្នកត្រូវបានគេបដិសេធលើការស្នើសុំបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកដឹកជញ្ជូនតាំងពីដំបូង តើអ្នកមានផែនការដាក់ពាក្យសុំលិខិតលើកលែងឬទេ ? | ☐ បាទ ☐ ទេ |
| ៧- ខ្ញុំយល់ហើយថា ខ្ញុំត្រូវប្រគល់បណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូនរបស់ខ្ញុំអោយទៅគេវិញតាមអាសយ័ដ្ឋានដែលមាននៅលើបណ្ណ័សំគាល់ បើសិនជា:<br>• ខ្ញុំជាមនុស្សដែលគេស្វែងរកចាប់ខ្លួន ក្រោមដីការចោទប្រកាន់ ត្រូវថ្កោលទោស ឬត្រូវរកឃើញថាគ្មានទោសដោយសារជំងឺសរសៃប្រសាទ នៅក្នុងបទឧក្រិដ្ឋដូចមានចែងក្នុងផ្នែក ខ១ រហូតដល់ ខ៣<br>• ខ្ញុំបានត្រូវគេរកឃើញថាជាមនុស្សដែលមានសតិបញ្ញាមិនគ្រប់គ្រាន់ ឬ ខ្ញុំបានព្យាបាលជំងឺសសៃប្រសាទនេះដោយបង្ខំ នៅក្នុងមន្ទីរពេទ្យ ឬ<br>• ខ្ញុំមិនអាចបំពេញឱ្យគ្រប់តាមបទដ្ឋានអន្តោប្រវេសន៏ ដូចបានបង្ហាញតាមចំឡើយ "បាទ" នៅក្នុងផ្នែក ក៥ | ☐ បាទ ☐ ទេ |

## ភាគ ២ — ការបញ្ជាក់

សូមពិនិត្យសាជាថ្មីឡើងវិញ និងសូមបញ្ជាក់លើចំឡើយទាំងអស់ ដែលផ្តល់នៅក្នុងពាក្យសុំនេះ ដោយសរសេរឈ្មោះ និងចុះហត្ថលេខារបស់អ្នក ព្រមទាំងថ្ងៃ-ខែ-ឆ្នាំ ផង ។ បើសិនជាមានការផ្តល់អោយជាជំនួយ/ការបកប្រែ ត្រូវទាមទារអោយមានពតិមានសំរាប់ទាក់ទងសំរាប់អ្នកជួយ/អ្នកបកប្រែធ្វើការតាមដាន ក្នុងករណីចាំបាច់ ។ **ចំពោះអ្នកដាក់ពាក្យសុំចូលធ្វើការទាំងឡាយ និងអ្នកជួយ/អ្នកបកប្រែដែលដឹងនិងតាំងចិត្តផ្តល់ចំឡើយបន្លំ ឬការមិនបញ្ចូលចំណុចសំខាន់ៗនៅក្នុងពាក្យស្នើសុំនេះ អាចនឹងត្រូវទទួលទោសដោយការផាកពិន័យ ឬ ការដាក់ពន្ធនាគារ ឬ ទាំងពីរមុខតែម្តង (សូមមើល ១៨ U.S.C. ១០០១) ហើយអាចជាមូលហេតុសំរាប់បដិសេធការស្នើសុំបណ្ណ័ សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន ។**

| | |
|---|---|
| **អ្នកដាក់ពាក្យសុំធ្វើការ:** ពតិមានដែលខ្ញុំផ្តល់ជូនក្នុងពាក្យស្នើសុំនេះគឺជាការពិត ពេញលេញ និងត្រឹមត្រូវបំផុតតាមការដឹង និងជំនឿរបស់ខ្ញុំ ហើយនិងផ្តល់ជូនដោយស្មោះត្រង់ ។ | **អ្នកជួយ/អ្នកបកប្រែ:** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានជួយបំពេញពាក្យស្នើសុំនេះ តាមសំណើរបស់អ្នកដាក់ពាក្យសុំធ្វើការ ចំឡើយដែលផ្តល់ជូនទាំងអស់ នេះ គឺយោងទៅតាមពតិមានដែលខ្ញុំដឹង ឬផ្តល់អោយដោយអ្នកដាក់ពាក្យ សុំធ្វើការ ហើយខ្ញុំបានអានពាក្យស្នើសុំដែលបំពេញរួចហើយនេះ អោយគាត់ស្តាប់ជាភាសា ដែលគាត់និយាយបានយ៉ាងស្ទាត់ជំនាញ មុនពេលដែល គាត់ចុះហត្ថលេខាលើពាក្យស្នើសុំនេះ នៅចំពោះមុខវត្តមានរបស់ខ្ញុំ ។ |
| សសេរឈ្មោះអ្នកសុំបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកដឹកជញ្ជូន | សសេរឈ្មោះអ្នកជួយ/អ្នកបកប្រែ |
| ចុះហត្ថលេខាអ្នកសុំបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកដឹកជញ្ជូន និងថ្ងៃ-ខែ-ឆ្នាំ | ចុះហត្ថលេខាអ្នកជួយ/អ្នកបកប្រែ ថ្ងៃ-ខែ-ឆ្នាំ |

| | |
|---|---|
| | |
| | លេខទូរសព្ទ័ពេលថ្ងៃ |
| | អាសយ័ដ្ឋាន លេខបន្ទប់ |
| | ឈ្មោះទីក្រុង រដ្ឋ លេខកូដ |

**<u>ការបញ្ជាក់នៃច្បាប់ស្តីពីការសំងាត់ឯកជនៈ</u> ច្បាប់អនុញ្ញាតៈ** ច្បាប់អនុញ្ញាតអោយប្រមូលពតិមានទាំងនេះគឺ លេខ ៤៩ U.S.C.១១៤ ៤០១១៣ និង ៥១០៣ក ។ **គោលបំណងសំខាន់១:** គេត្រូវការពតិមានទាំងនេះ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នក និង ដើម្បីធ្វើការវាយតំលៃលើការគំរាមកំហែងសន្តិសុខ ដើម្បីដឹងថា តើអ្នកសក្តសមនឹងទទួលបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូនដែរឬទេ ។ ការផ្តល់ពតិមានទាំង អស់នេះ ដោយរាប់ទាំងលេខសន្តិសុខសង្គមរបស់អ្នកផង ឬ លេខចុះបញ្ជីជនបរទេស គឺផ្តល់ដោយការស្មគ្រ័ ចិត្ត ក៏ប៉ុន្តែការដែលមិនបានផ្តល់ពតិមានទាំងនេះ អាចនឹងពន្យាពេលហើយនឹងអាចរាំងស្ទះ ក្នុងការបំពេញ ការវាយតំលៃលើភាពគំរាមកំហែងសន្តិសុខរបស់អ្នកបាន ។ ចំពោះជនទាំងឡាយណា ដែលជាអ្នកដើរកប៉ាល់ ឬ ដាក់ពាក្យសុំធ្វើជាអ្នកដើរកប៉ាល់, លេខសន្តិសុខសង្គមគឺជាការចាំបាច់ ឬ ពួកគេនឹងត្រូវទាមទារអោយ ទៅកាន់មណ្ឌលត្រួតពិនិត្យឆ្នាំសមុទ្រប្រចាំតំបន់ ដើម្បីផ្តល់ពតិមានទាំងនេះ មុនពេលការស្នើសុំត្រូវបញ្ចប់ ពេញលេញ ។ **ការប្រើប្រាស់ជាទូទៅ:** ការប្រើប្រាស់ជាទូទៅនូវពតិមានទាំងនេះ មានរាប់បញ្ចូលទាំងការ បង្ហាញចំពោះទីភ្នាក់ងារស៊ើបអង្កេតសហព័ន្ធ ដើម្បីដកស្រង់កំណត់ត្រាប្រវត្តិឧក្រិដ្ឋកម្មរបស់អ្នក, បង្ហាញ ចំពោះអ្នកចុះកិច្ចសន្យាការគ្រប់គ្រងសន្តិសុខនៃការដឹកជញ្ជូន ឬចំពោះភ្នាក់ងារផ្សេង១ទៀត ដែលផ្តល់សេវា កម្មទាក់ទងទៅនឹងការវាយតំលៃលើភាពគំរាមកំហែងសន្តិសុខ; ចំពោះទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីផ្តល់ការអនុញ្ញាត; ការអនុវត្តច្បាប់ ឬបុព្វហេតុសន្តិសុខ; ឬផលប្រយោជន៍សន្តិសុខជាតិ; និងចំពោះ អាជ្ញាធរនៃរដ្ឋាភិបាលបរទេស និងអន្តរជាតិ ស្របតាមច្បាប់និងកិច្ចព្រមព្រៀងអន្តរជាតិ ។

**<u>សេចក្តីបញ្ជាក់នៃច្បាប់ស្តីពីការកាត់បន្ថយលិខិតស្នាមការងារៈ</u>សេចក្តី**បញ្ជាក់ពីបន្ទុកសាធារណៈ ការគ្រប់គ្រង សន្តិសុខនៃការដឹកជញ្ជូនប្រមូលពតិមានទាំងនេះ ដើម្បីកំណត់ភាពស្របច្បាប់របស់អ្នកក្នុងការសុំបណ្ណ័សំគាល់ អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន។ នេះគឺជាការប្រមូលពតិមានដោយស្មគ្រ័ចិត្ត ប៉ុន្តែការមិនបានផ្តល់ពតិ មាន អាចបណ្តាលអោយគេពុំមានលទ្ធភាពសំរេចលើភាពស្របច្បាប់របស់អ្នក ក្នុងការទទួលបណ្ណ័សំគាល់អត្ត សញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន ។ ការគ្រប់គ្រងសន្តិសុខនៃការដឹកជញ្ជូនបានប៉ាន់ប្រមាណថា បន្ទុកសារុប ជាមធ្យមចំពោះការផ្តល់ចំឡើយនិមួយ១ ទាក់ទងនឹងការប្រមូលពតិមានសំរាប់ការចុះឈ្មោះ គឺប្រហែល ៩០នាទី ។ ទីភ្នាក់ងារអាចមិនធ្វើ ឬមិនឧបត្ថម្ភ ហើយអ្នកដាក់ពាក្យមិនត្រូវបានទាមទារអោយឆ្លើយដើម្បី ប្រមូលពតិមាន ប្រសិនបើពតិមានទាំងនេះមិនបង្ហាញលេខត្រួតពិនិត្យ OMB ដែលនៅប្រើការបាន។ លេខ ត្រួតពិនិត្យដែលដាក់សំរាប់ការប្រមូលពតិមាននេះគឺ OMB១៦៥២-00៤៧ ដែលនឹងផុតកំណត់នៅថ្ងៃទី ៣១ កក្កដា ២០១១ ។

**ខ្ញុំមិនមែនជាពលរដ្ឋអាមេរិក ឬ ជនជាតិអាមេរិកទេ ប៉ុន្តែស្ថិតនៅក្នុងប្រភេទមួយនៃបញ្ជីខាងក្រោម ដែលអនុញ្ញាតអោយខ្ញុំកាន់បណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូន។**

១- អ្នករស់នៅអចិន្ត្រៃយ៍ដោយស្របច្បាប់នៅសហរដ្ឋអាមេរិក

២- ជនភៀសខ្លួនដែលត្រូវបានទទួលក្រោមច្បាប់ ៨ U.S.C. ១១៥៧

៣- ជនបរទេសដែលបានទទួលសិទ្ធិជ្រកកោនក្រោមច្បាប់ ៨ U.S.C. ១១៥៨

៤- ជនបរទេសកាន់ទិដ្ឋាការប្រភេទ M-1 ដែលនៅមាន សុពលភាព មិនមែនជាជនអន្តោប្រវេសន៍ ហើយបានចុះឈ្មោះនៅបណ្ឌិតសភាអាមេរិកផ្នែកនាវាជំនួញ ឬនៅបណ្ឌិតសភានាវាដូចគ្នានេះ នៅតាមរដ្ឋណាមួយក៏បាន ។

៥- ពលរដ្ឋនៃប្រទេសមីក្រូនេស៊ី កោះម៉ាសល ឬប៉ាឡូ។

៦- អ្នកមានបណ្ណ័បើកបរប្រភេទពាណិជ្ជកម្ម នៅក្នុងប្រទេស កាណាដា និងម៉ិចស៊ិកូ សំរាប់ដឹកជញ្ជូនសំភារៈដែលមាន េ គ្រោះថ្នាក់ ឬដែលសហរដ្ឋអាមេរិកអនុញ្ញាតអោយចូលមកធ្វើជំនួញក្រោមច្បាប់ ៨ CFR ២១៤.២ (b)(4)(i)(E) ។

៧- ជនបរទេសដែលមានច្បាប់អនុញ្ញាតអោយធ្វើការងារនៅក្នុងសហរដ្ឋអាមេរិក ដោយគ្មានកាលកំណត់ ហើយកាន់ទិដ្ឋាការប្រភេទណាមួយ ក្នុងចំណោមទិដ្ឋាការខាងក្រោមៈ

- A-1: សមាជិកគ្រួសារផ្ទាល់របស់ឯកអគ្គរដ្ឋទូត រដ្ឋមន្រ្តី អ្នកការទូតអាជីព មន្ត្រីកុងស៊ុល ប្រមុខរដ្ឋ ដែលមានកិច្ចព្រមព្រៀងទ្វេភាគីកំពុងដំណើរការ
- A-2: សមាជិកគ្រួសារផ្ទាល់របស់មន្ត្រីផ្សេងទៀតនៃរដ្ឋាភិបាលបរទេស ឬ នយោជិកដែលចូលមកសហរដ្ឋអាមេរិករួមទាំងបុគ្គលិកបច្ចេកទេសនិងជំនួយការរបស់អ្នកកាន់ A-1 ដែលមានកិច្ចព្រមព្រៀងទ្វេភាគីកំពុងដំណើរការ ។
- A-13: ការជួបជុំគ្រួសារ
- E-1: ប្តី/ប្រពន្ធ និងកូនក្នុងបន្ទុករបស់អ្នកជំនួញ ដែលមានកិច្ចសន្យាពាណិជ្ជកម្ម។
- E-2: ប្តី/ប្រពន្ធ របស់អ្នកវិនិយោគ ដែលមានកិច្ចសន្យាពាណិជ្ជកម្ម ឬ ប្តី/ប្រពន្ធ របស់នយោជិកនៃអ្នកវិនិយោគ ដែលមានកិច្ចសន្យាពាណិជ្ជកម្ម។
- S-7: ប្តី/ប្រពន្ធ កូនប្រុស-ស្រីដែលនៅលីវ និងឪពុកម្តាយ របស់សាក្សី ឬអ្នកដែលផ្តល់ពត៌មាន
- T-1: ជនរងគ្រោះដោយសារការជួញដូរមនុស្សក្នុងទំរង់ធ្ងន់ធ្ង
- T-2: ប្តី/ប្រពន្ធ របស់ជនរងគ្រោះដោយសារការជួញដូរមនុស្សក្នុងទំរង់ធ្ងន់ធ្ង
- T-3: កូន របស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស ក្នុងទំរង់ធ្ងន់ធ្ង
- T-4: ឪពុកម្តាយ របស់ជនរងគ្រោះដោយសារការជួញដូរមនុស្សក្នុងទំរង់ធ្ងន់ធ្ង (បើសិនជាអ្នកកាន់ T-1 មានអាយុ ក្រោម ២១ ឆ្នាំ)
- T-5: បងប្អូនប្រុសស្រីដែលនៅលីវ និងមានអាយុក្រោម ១៨ ឆ្នាំ របស់អ្នកកាន់ T-1 ដែលមានអាយុក្រោម ២១ ឆ្នាំ
- U-1: ជនរងគ្រោះនៃអំពើឧក្រិដ្ឋ
- U-2: ប្តី/ប្រពន្ធរបស់អ្នកកាន់ U-1
- U-3: កូនរបស់អ្នកកាន់ U-1
- U-4: ឪពុកម្តាយរបស់អ្នកកាន់ U-1 (បើសិនជាអ្នកកាន់ U-1 មានអាយុក្រោម ២១ ឆ្នាំ)
- U-5: បងប្អូនប្រុសស្រីដែលនៅលីវ និងមានអាយុក្រោម ១៨ ឆ្នាំ របស់អ្នកកាន់ U-1 ដែលមានអាយុក្រោម ២១ ឆ្នាំ
- V-1: ប្តី/ប្រពន្ធរបស់អ្នករស់នៅអចិន្ត្រៃយ៍ស្រប ច្បាប់ ដែលជាអ្នកទទួលផលផ្ទាល់ ពីសំណើសុំទិដ្ឋាការជាលក្ខណៈគ្រួសារ ដែលបានស្នើសុំមុនថ្ងៃ ទី ២១ ធ្នូ ឆ្នាំ ២០០០ និង ដែលត្រូវបានគេព្យួរទុកអស់រយៈពេលយ៉ាង តិច ៣ ឆ្នាំ
- V-2: កូនរបស់អ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ ដែលជាអ្នកទទួល ផលផ្ទាល់ពីសំណើសុំទិដ្ឋាការជា

- G-1: សមាជិកគ្រួសារផ្ទាល់របស់អ្នកធ្វើការជាតំណាងនៃរដ្ឋាភិបាលបរទេស ដែលគេទទួលស្គាល់ជាសមាជិកនៃអង្គការអន្តរជាតិ និងបុគ្គលិក ដែលមានកិច្ចព្រមព្រៀងទ្វេភាគីកំពុងដំណើរការ ។
- G-3: សមាជិកគ្រួសារផ្ទាល់របស់តំណាង នៃរដ្ឋាភិបាល បរទេសដែលគេមិនទទួលស្គាល់ ឬមិនមែនជាសមាជិកនៃអង្គការអន្តរជាតិ ដែលមានកិច្ចព្រមព្រៀងទ្វេភាគីកំពុងដំណើរការ ។
- G-4: សមាជិកគ្រួសារផ្ទាល់របស់មន្ត្រីនៃអង្គការអន្តរជាតិ ឬនយោជិកដែលមានកិច្ចព្រមព្រៀងទ្វេភាគី
- J-2: ប្ដី/ប្រពន្ធ ឬកូនមិនទាន់ពេញវ័យរបស់អ្នកចូលរួមកម្មវិធីផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមក
- K-3: ប្ដី/ប្រពន្ធរបស់ពលរដ្ឋអាមេរិក (ក្រោមបទដ្ឋាននៃច្បាប់ស្ដីពីគោលការណ៍យុត្តិធម៌សំរាប់គ្រួសារអន្តោប្រវេសន៍ស្របច្បាប់)
- K-4: កូនរបស់អ្នកដែលជា K-3;
  L-2: ប្ដី/ប្រពន្ធ ឬកូនរបស់អ្នកដែលជា L-1
- N-8: ឳពុកម្ដាយរបស់ជនបរទេស ដែលចាត់ទុកក្នុង ប្រភេទ SK-3 “អន្តោប្រវេសន៍ពិសេស”
- N-9: កូនរបស់អ្នកដែល ជា N-8, SK-1, SK-2, ឬ SK-4 “អន្តោប្រវេសន៍ពិសេស”
- សមាជិកគ្រួសារផ្ទាល់របស់មន្ត្រីនៃអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (NATO) និងអ្នកតំណាងទាំងឡាយដែលមានកិច្ចព្រមព្រៀងទ្វេភាគីកំពុងដំណើរការ សំរាប់ប្រភេទទិដ្ឋាការដូចខាងក្រោម:
  - NATO-1 អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង -១
  - NATO-2 អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង -២
  - NATO-3 អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង -៣
  - NATO-4 អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង -៤
  - NATO-5 អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង -៥

លក្ខណៈគ្រួសារ ដែលបានស្នើសុំមុនថ្ងៃទី ២១ ធ្នូ ឆ្នាំ ២០០០ និងដែលត្រូវបានគេ ព្យួរទុកអស់រយៈពេលយ៉ាង តិច ៣ ឆ្នាំ

- V-3: កូនដែលមានជាប់ខ្សែស្រឡាយជាមួយអ្នក កាន់ V-1 ឬ V-2 ឬ
- TPS: ស្ថានភាពការពារបណ្ដោះអាសន្ន (TPS) ។

៨- ជនបរទេសដែលអនុញ្ញាតអោយធ្វើការនៅក្នុងសហរដ្ឋអាមេរិកដោយមានកាលកំណត់ និងកាន់ទិដ្ឋាការណាមួយ ក្នុងចំណោមប្រភេទទិដ្ឋាការដូចខាងក្រោម:

- B1-OCS: ទេសចរផ្នែកជំនួញ/ក្រៅដែនសមុទ្រ (OCS)
- C-1/D:ទិដ្ឋាការរួមសំរាប់ចូលសំចតនិងក្រុមនាវិក
- E-1(មេគ្រួសារ): អ្នកជំនួញដែលមានកិច្ចសន្យាពាណិជ្ជកម្ម និងនយោជិករបស់គាត់
- E-2(មេគ្រួសារ): អ្នកវិនិយោគដែលមានកិច្ចសន្យាពាណិជ្ជកម្ម និងនយោជិករបស់គាត់
- E-3: ជនជាតិអូស្ត្រាលីដែលធ្វើការនៅក្នុងអាជីពពិសេស ដោយរួមទាំងប្ដី/ប្រពន្ធ
- H-1B: អ្នកមានអាជីពពិសេស
- L-1A: អ្នកកាន់កាប់ អ្នកគ្រប់គ្រង (អ្នកផ្ទេរការងារក្នុងក្រុមហ៊ុន)
- L-1B: អ្នកជំនាញឯកទេស
- M-3: ជនជាតិកាណាដា និងម៉ិចស៊ិកូដែលជានិស្សិតត្រូវធ្វើ ដំណើរមករៀនជាប្រចាំ
- O-1A: អ្នកមានសមត្ថភាពពិសេស ផ្នែកវិទ្យា សាស្ត្រ សិល្បៈ ការអប់រំ ជំនួញ អត្តពលកម្ម
- O-1B: អ្នកមានស្នាដៃពិសេសខាងគំនូរជីវចល និង/ឬផលិតកម្មទូរទស្សន៍ ឬ
- TN: ទិដ្ឋាការពាណិជ្ជកម្មសំរាប់ជនជាតិកាណាដា និងម៉ិចស៊ិកូ ដែលស្វែងរកការងារជំនាញ ក្រោមកិច្ច

| | |
|---|---|
| - NATO-6 អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង -៦ | ក្រុមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA)<br>**កំណត់ចំណាំ: ប្រភេទទិដ្ឋាការខាងក្រោម ដែលអនុញ្ញាតអោយធ្វើការដោយគ្មានកំណត់ មិនត្រូវបានអនុញ្ញាតអោយមានបណ្ណ័សំគាល់អត្តសញ្ញាណជាអ្នកធ្វើការដឹកជញ្ជូនឡើយ:**<br>▪ S-5: អ្នកផ្តល់ដំណឹងនៃអង្គការពតិមានឧក្រិដ្ឋកម្ម<br>▪ S-6: អ្នកផ្តល់ដំណឹងនៃអង្គការពតិមានភេរវកម្ម<br>▪ K-1: គូរដណ្តឹងប្រុស-ស្រីរបស់ពលរដ្ឋអាមេរិក ឬ<br>▪ K-2: កូនមិនទាន់ពេញវ័យរបស់អ្នកកាន់ K-1 |

## ការដកហូតសិទ្ធិដោយសារបទល្មើសឧក្រិដ្ឋកម្ម (៤៩ C.F.R. ១៥៧២.១០៣)

### ខ្ទង់អត្ថបទ ក

**ការកាត់អោយជាប់ទោសណាមួយ ក្នុងចំណោមទោស ឧក្រិដ្ឋខាងក្រោម គឺជាការដកហូតសិទ្ធិ ដោយមិនគិតថាវាកើតមាននៅពេលណា ហើយអ្នកសុំចូលធ្វើការមិនមានសិទ្ធិសំរាប់លិខិតលើកលែងអ្វីមួយឡើយ ។**

១- ចារកម្ម ឬ ការរួមគំនិតក្នុងការធ្វើចារកម្ម ។

២- ការនាំបះបោរ ឬ ការរួមគំនិតក្នុងការនាំបះបោរ ។

៣- ការក្បត់ជាតិ ឬ ការរួមគំនិតក្បត់ជាតិ ។

៤- បទឧក្រិដ្ឋភេរវកម្មសហពន្ធ័ដូចមានចែងនៅក្នុង លេខ ១៨ U.S.C.២៣៣២b(g) ឬ ច្បាប់នៃរដ្ឋ ផ្សេងៗ ដែលដូចគ្នា ឬ ការរួមគំនិតក្នុងការប្រព្រឹត្ត ឧក្រិដ្ឋកម្មបែបនេះ ។

**ការកាត់អោយជាប់ទោសណាមួយ ក្នុងចំណោមទោស ឧក្រិដ្ឋខាងក្រោម គឺជាការដកហូតសិទ្ធិ ដោយមិនគិតថាវាកើតមាននៅពេលណា ហើយអ្នកសុំចូលធ្វើការអាចដាក់ពាក្យសុំលិខិត លើកលែងអ្វីមួយបាន ។**

៥- ឧក្រិដ្ឋកម្មដែលទាក់ទងនឹងឧប្បត្តិហេតុនៃសន្តិសុខ ដឹកជញ្ជូន ។ ឧប្បត្តិហេតុនៃសន្តិសុខដឹកជញ្ជូនគឺជា ឧប្បត្តិហេតុសន្តិសុខ ដែលបង្កអោយមានការបាត់បង់ ជីវិត ខូចខាតបរិស្ថាន ការបង្អាក់ប្រពន្ធ័ដឹកជញ្ជូន ឬ ការបង្អាក់សេដ្ឋកិច្ចនៅតំបន់ណាមួយ ដូចបានកំណត់នៅ ក្នុង លេខ ៤៦ U.S.C.៧០១០១ ។ ពាក្យ "ការបង្អាក់សេដ្ឋកិច្ច" មិនរាប់បញ្ចូលការឈប់ធ្វើការងារ ឬ សកម្មភាពពាក់ពន្ធ័របស់នយោជិក ដែលមិនទាក់ទងនឹង អំពើភេរវកម្ម និងដែលជាលទ្ធផលចេញពីជំលោះរវាង នយោជក- នយោជិក ។

៦- ការដឹកជញ្ជូនមិនត្រឹមត្រូវនៃសំភារៈប្រកបដោយ គ្រោះថ្នាក់ក្រោមច្បាប់ ៤៩ U.S.C.៥១២៤ ឬ ច្បាប់ របស់រដ្ឋផ្សេងៗ ដែលដូចគ្នា ។

### ខ្ទង់អត្ថបទ ខ

**ការកាត់អោយជាប់ទោសណាមួយ ក្នុងចំណោមទោស ឧក្រិដ្ឋខាងក្រោម គឺជាការដកហូតសិទ្ធិ ប្រសិនបើអ្នក សុំចូលធ្វើការត្រូវបានកាត់ក្តីអោយមានទោស ឆ្លើយ ទទួលកំហុស (រួមទាំង "ការមិនប្រឆាំងតវ៉ា") ឬត្រូវ បានរកឃើញថាមិនមានកំហុស ដោយមូលហេតុនៃជំងឺ សរសៃប្រសាទ នៅក្នុងរយៈពេល ៧ ឆ្នាំ គិតតាំងពីថ្ងៃ ដែលដាក់ពាក្យសុំបណ្ណ័សំគាល់អត្តសញ្ញាណ ជាអ្នកធ្វើការដឹកជញ្ជូន ឬប្រសិនបើអ្នកសុំចូលធ្វើការត្រូវបានដោះលែងចេញពីមន្ទីរឃុំឃាំង បន្ទាប់ពីជាប់ទោសក្នុងរវាង ៥ ឆ្នាំ គិតតាំងពីថ្ងៃដែលដាក់ពាក្យសុំចូលធ្វើការ ។ អ្នកសុំចូលធ្វើការអាចស្នើសុំលិខិតលើកលែងអ្វីមួយបាន ។**

១- កម្មសិទ្ធិមិនស្របច្បាប់ ការប្រើប្រាស់ ការលក់ ការផលិត ការទិញ ការចែកចាយ វិកយ័បត្រ័ ការបញ្ជូន ការដឹកនាំតាមកប៉ាល់ ការដឹកជញ្ជូនប្រគល់ដល់កន្លែង ការនាំចូល ការនាំចេញ ឬពាក់ពន្ធ័នឹងកាំភ្លើងដៃ ឬ សព្វាវុធផ្សេងទៀត ។ កាំភ្លើងដៃ ឬ សព្វាវុធផ្សេងទៀត មានរាប់បញ្ចូលកាំភ្លើងដៃទាំងឡាយ ដូចមានកំណត់ នៅក្នុង ១៨ U.S.C.៩២១ (a)(៣) ឬ ២៦ U.S.C. ៥៨៤៥ (a) ឬវត្ថុដែលមានចែងនៅក្នុងបញ្ជីអាមេរិកស្តីពីការនាំចូលគ្រាប់រំសេវ នៅ ២៧ CFR ៤៤៧.២១

២- ការគំរាមកំហែងយកប្រាក់

៣- ភាពមិនស្មោះត្រង់ ការបន្លំ ឬ ការក្លែងធ្វើជាតំណាង រួមទាំការបន្លំអត្តសញ្ញាណ ការលាងលុយក្រខ្វក់ ដែលកន្លែងលាងលុយក្រខ្វក់នេះ ជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្ម ដែលបានរៀបរាប់នៅក្នុងខ្ទង់អត្ថបទ ក និង ខ ។ ការបន្លំប្រាក់សង្គ្រោះ និង ការប្រើសែកដែលគ្មានលុយ មិនបង្កភាពមិនស្មោះត្រង់ ការបន្លំ ឬ ការក្លែងធ្វើជាតំណាង ដែលជាគោលបំណងនៃកថាខណ្ឌនេះ ។

៧- កម្មសិទ្ធិមិនស្របច្បាប់ ការប្រើប្រាស់ ការលក់ ការចែកចាយ ការផលិត ការទិញ វិកយ័បត្រ ការ បញ្ជូន ការដឹកនាំតាមកប៉ាល់ ការដឹកជញ្ជូន ការនាំ ចូល ការនាំចេញ ការរៀបទុកក្នុងឃ្លាំង ឬ ពាក់ពន្ធ័ នឹងវិសេវផ្ទុះ ឬគ្រឿងផ្ទុះ ។ វិសេវផ្ទុះ ឬ គ្រឿងផ្ទុះ មានរាប់បញ្ចូលវិសេវផ្ទុះ ឬសំភារៈផ្ទុះ ដូចមានកំណត់ នៅក្នុង ១៨ U.S.C.២៣២ (៥) ៨៤១ (c) រហូតដល់ ៨៤១ (f) និង ៨៤៤ (j) និងគ្រឿងដែលធ្វើអោយ គ្រោះថ្នាក់ ដូចមានកំណត់នៅក្នុង ១៨ U.S.C. ៩២១ (a)(៤) និង ២៦ U.S.C.៥៨៤៥ (f) ។

៨- ឃាតកម្ម

៩- ធ្វើការគំរាមកំហែងណាមួយ ឬក្នុងបំណងអាក្រក់ នាំពតិមានក្លែងក្លាយ ដែលដឹងថាមិនពិត ដែលទាក់ទង នឹងការប្រគល់ដល់កន្លែង ការដាក់ ឬ ការធ្វើអោយផ្ទុះ គ្រឿងវិសេវ ឬ គ្រឿងផ្ទុះផ្សេងៗ ដែលបណ្តាលអោយ ស្លាប់បាន នៅក្នុង ឬនៅ ក្បែរកន្លែងដែលប្រើប្រាស់ជា សាធារណៈ អាគាររដ្ឋ ឬអាគាររដ្ឋាភិបាល ប្រពន្ធ័ដឹក ជញ្ជូនសាធារណៈ ឬ ហេដ្ឋារចនាសម្ពន្ធ័ ផ្សេងៗ ។

១០- ការរំលោភច្បាប់ស្តីពី អ្នកបោកប្រាស និងការ បង្កអំពើពុករលួយ ១៨ U.S.C.១៩៦១ និងច្បាប់ បន្តបន្ទាប់ទៀត ឬ ច្បាប់នៃរដ្ឋផ្សេងៗទៀតដែលដូចគ្នា ដែលតុលាការបានរកឃើញបទឧក្រិដ្ឋមួយ ក្នុងចំណោម បទល្មើស ដែលមាននៅក្នុងច្បាប់ទាំងនេះ ឬ ដែលជន ចុងចោទយល់ព្រមទទួលបទឧក្រិដ្ឋមួយ ក្នុងចំណោម ឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងខ្ទង់អត្ថបទ ក ។

១១- ប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋដែលមាននៅក្នុងខ្ទង់ អត្ថបទ ក ចំណុច ១ ដល់ ៤ ។

១២- ការរួមគំនិត ឬ ប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ដែលមាននៅ ក្នុងខ្ទង់អត្ថបទ ក ចំណុច ៥ ដល់ ១០ ។

៤- ការស៊ីសំណូក

៥- ការរត់ពន្ធ

៦- ការរំលោភច្បាប់អន្តោប្រវេសន្ត៍

៧- ការចែកចាយ ការមានជាប់នឹងខ្លួនក្នុងគោលបំណង ចង់ចែកចាយ ឬ ការនាំចូលនូវសារធាតុគ្រឿងញៀន

៨- ការបង្កអោយមានអគ្គីភយ័

៩- ការចាប់ជំរត់ ឬចាប់ជាចំណាប់ខ្មាំង

១០- ការចាប់រំលោភ ឬការរំលោភផ្លូវភេទដ៏ធ្ងន់ធ្ងរ

១១- ការវាយតប់ក្នុងគោលបំណងចង់សំលាប់

១២- ការប្លន់

១៣- ការបន្លំចូលទៅក្នុងកំពង់ផែ ដូចបានរៀបរាប់ក្នុង ១៨ U.S.C. ១០៣៦ ឬ ច្បាប់នៃរដ្ឋផ្សេងៗ ដែលដូចគ្នា

១៤- ការរំលោភច្បាប់ស្តីពី អ្នកបោកប្រាស និងការបង្ក អំពើពុករលួយ ១៨ U.S.C.១៩៦១ និងច្បាប់បន្ត បន្ទាប់ទៀត ឬ ច្បាប់នៃរដ្ឋផ្សេងៗទៀតដែលដូចគ្នា ក្រៅពីការរំលោភច្បាប់ ដែលមានចែងនៅក្នុងខ្ទង់ អត្ថបទ ក ចំណុចលេខ ១០ ។

១៥- ការរួមគំនិត ឬប៉ុនប៉ងធ្វើឧក្រិដ្ឋកម្ម ដូចមាន ចែងក្នុង ខ្ទង់អត្ថបទ ខ ។